Australian Aid
PONLOK CHOMNES
The Asia Foundation

# សេចក្ដីផ្ដើម
# ស្ដីពី
# “ការសិក្សាស្រាវជ្រាវបែបចូលរួម ផ្អែកលើគោលការណ៍ហ្វេមីនីស្ត”

ថ្ងៃទី ២៤ ខែធ្នូ ឆ្នាំ ២០២៤

សហរៀបចំដោយ៖

GADC

Women Peace Makers

# តស់! ដល់ពេល មកស្គាល់គ្នាបន្តិច!!!



1. ណែនាំឈ្មោះនិងទីតាំងស្រុកកំណើត
2. មុខងារនិងស្ថាប័ន
3. សត្វដែលអ្នកចូលចិត្តនិងខ្លាច
4. ការតាំងចិត្តនិងការរំពឹងទុកសម្រាប់ថ្ងៃនេះ

# ការបង្កើតបរិយាកាស បរិយាបន្ននិង អំណោយផល សម្រាប់វគ្គ



# ដំណើរមេរៀន

១. តើអ្វីជា FPAR? ហេតុអ្វី FPARមានសារៈសំខាន់?

2. គោលការណ៍ FPAR

៣. សេចក្តីសង្ខេបវិធីសាស្រ្តស្រាវជ្រាវនិងក្រមសីលធម៌ FPAR

4. ករណីសិក្សា FPAR និងផលជះ

៥. កិច្ចពិភាក្សាពី បញ្ហាប្រឈម ឳកាស នឹង ជំហានបន្ទាប់



# មាតិកា



តើការសិក្សាស្រាវជ្រាវបែបចូលរួមផ្អែកលើគោលការណ៍ហ្វេមីនីស្តគឺជាអ្វី?
Feminist Participatory Action Research (FPAR)




គោលការណ៍
FPAR
Feminist Participatory Action Research




សង្ខេបវិធីសាស្ត្រស្រាវជ្រាវ FPAR និងក្រមសីលធម៌




ករណីសិក្សា និងមេរៀន




បញ្ហាប្រឈម ឱកាស និង, ជំហានបន្ទាប់

# តើការសិក្សាស្រាវជ្រាវបែបចូលរួមផ្អែកលើគោលការណ៍ហ្វេមីនីស្តជាអ្វី?

## Feminist Participatory Action Research (FPAR)



# អំពី "FPAR"

FPAR គឺវិធីសាស្ត្រស្រាវជ្រាវមួយប្រភេទដែលរួមបញ្ចូលទស្សនទាន ហ្វេមីនីស្ត និងគោលការណ៍ស្រាវជ្រាវសកម្មបែបចូលរួម ដើម្បីស្វែងយល់បញ្ហានិងធ្វើសកម្មភាពក្នុងការផ្លាស់ប្តូរជាវិជ្ជមាននូវរចនាសម្ព័ន្ធ និងទំនាក់ទំនងនៃអំណាចដែលគាបសង្កត់ដ៏ស្មុគស្មាញ និងដែលធ្វើឱ្យប៉ះពាល់ដល់យុត្តិធម៌សង្គម។




ស្នូលរបស់ FPAR៖

- ការពង្រឹងភាពអង់អាចរបស់ស្ត្រីនិងសហគមន៍ងាយរងគ្រោះក្នុងការបង្កើតចំណេះដឹងស្តីពីបទពិសោធន៍របស់ពួកគេ មិនត្រឹមតែជា "អ្នកប្រមូលទិន្នន័យ" ថែមទាំងចូលរួមនៅគ្រប់ដំណាក់កាលទាំងអស់នៃការស្រាវជ្រាវ។
- សកម្មភាពរួមគ្នាក្នុងការធ្វើអោយមានការកែប្រែជាវិជ្ជមាន

# ជំហាននិងវិធីសាស្ត្រនីមួយៗអាចបត់បែន និង ផ្លាស់ប្តូរបាន ប៉ុន្តែគោលការណ៍ដែលសំខាន់បំផុតនោះគឺ

១. គោលការណ៍ ហ្វេមីនីស្ត ត្រូវបានដាក់បញ្ចូលក្នុងគ្រប់ដំណាក់កាលនៃការស្រាវជ្រាវ និងសកម្មភាព ( “Feminist” element in FPAR )

- បំបែកផ្ទត់គំនិតបិតាធិបតេយ្យអវិជ្ជមាន
- គោលការណ៍អន្តរប្រសព្វ
- សំឡេងស្ត្រីនិងក្រុមងាយរងគ្រោះដទៃទៀត



# អ្វីទៅជាអន្តរប្រសព្វ ?

មានន័យថាយើងផ្តោតការយកចិត្តដាក់ និងទទួលស្គាល់នូវឧបសគ្គនានាដែលជះឥទ្ធិពលដល់លទ្ធភាពនៃការទទួលបានសមភាពយេនឌ័ររបស់បុគ្គលម្នាក់ៗថា អាចមានច្រើនឬតិច អាស្រ័យលើកត្តាផ្សេងៗដែលពាក់ព័ន្ធនឹងអត្តសញ្ញាណរបស់បុគ្គលម្នាក់ៗ។ កត្តាទាំងនោះរួមមានដូចជា ពូជសាសន៍ អាយុ ឋានៈ និន្នាការភេទ ឬ ជំនឿសាសនា។ល។

ការប្រកាន់ខ្ជាប់នូវគោលការណ៍អន្តរប្រសព្វរបស់បុគ្គលហ្វេមនី មានន័យថា យើងព្យាយាមដោះស្រាយរាល់បញ្ហាចាក់ស្រេះរបស់ស្ត្រី និងក្រុមងាយរងគ្រោះដទៃទៀត ដែលក្នុងនោះរួមបញ្ចូលទាំង ក្រុមបុគ្គលដែលប្តូរយេនឌ័រ អន្តរភេទ និង បុគ្គលដែលមិនបានកំណត់អត្តសញ្ញាណយេនឌ័រផងដែរ។



# ឧទាហរណ៍៖

ស្ត្រីស្រឡាញ់ភេទដូចគ្នា ជនជាតិខ្មែរ មានវ័យក្មេង មានទ្រព្យស្តុកស្តម្ភ រស់នៅទីក្រុងភ្នំពេញ

និងស្ត្រីជនជាតិភាគតិច ក្រីក្រ ចាស់ជរា មានផ្ទុកមេរោគអេដស៍ នៅខេត្តឧត្តរមានជ័យ ទាំងពីរនាក់អាចជួបប្រទះការរើសអើងអត្តសញ្ញាភេទ (Sexism)។





ប៉ុន្តែ **តើវាមានន័យថាបទពិសោធន៍របស់ស្ត្រីទាំងអស់សុទ្ធតែដូចគ្នាឬយ៉ាងណា?**

តើអ្នកគិតយ៉ាងណាដែរ? តើបទពិសោធន៍របស់ពួកគេទំនងជាខុសគ្នាយ៉ាងណានៅក្នុងជីវិតពិត?

# ២. គោលការណ៍ ការចូលរួមពេញលេញប្រកបដោយអត្ថន័យ

( “Participatory” element in FPAR )

- ផ្ដោតលើអ្នកចូលរួមជាចម្បង
- សហគមន៍ជាអ្នកបង្កើតនិងជាម្ចាស់លើចំណេះដឹងនៃការស្រាវជ្រាវនេះ
- ( សហ- ) ដឹកនាំការរៀបចំផែនការ ការអនុវត្តរបាយការណ៍ និងសកម្មភាពបន្ទាប់។

# ការផ្លាស់ប្តូរចំណេះដឹង

អ្នកស្រាវជ្រាវក៏មានអ្វីច្រើនណាស់ដែលត្រូវរៀនសូត្រពីអ្នកត្រូវបានស្រាវជ្រាវ! ដូច្នេះ សកម្មភាពនេះជាដំណើរការនៃ**ការផ្លាស់ប្តូរការសិក្សាពីគ្នាទៅវិញទៅមក។**

ដំណើរការនេះគឺមានលក្ខណៈច្បាស់លាស់ និងផ្អែកទាំងស្រុងលើគោលការណ៍ហ្វេមីនីស្ត

យើងប្រកាន់ខ្ជាប់នូវគោលការណ៍នេះ តាមរយៈការអនុវត្តការស្រាវជ្រាវប្រកបដោយក្រមសីលធម៌ និងយុត្តិធម៌សង្គម ជាមួយនឹងការវិភាគយេនឌ័រដែលមានភាពប្រទាក់ក្រឡាគ្នា





# ៣. គាំទ្រសហគមន៍បង្កើនចំណេះដឹង និង ជំនាញក្នុងការធ្វើសកម្មភាព

(“Action” element in FPAR)



នៅក្នុង FPAR ការកសាងសមត្ថភាពគឺជាផ្នែកមួយនៃផ្នែកសំខាន់នៃដំណើរការស្រាវជ្រាវ។ វគ្គបណ្តុះបណ្តាលស្តីពីគន្លឹះបច្ចេកទេស និងផ្នែកនីមួយៗនៃក្នុងការស្រាវជ្រាវ ព្រមទាំងគោលការណ៍ និងតម្លៃគុណតម្លៃ **ហ្វេមីនីស្ត** ធ្វើឡើងដើម្បីធានាថាសមាជិកក្រុមគ្រប់រូបទទួលបានព័ត៌មាននិងជំនាញប្រហាក់ប្រហែលគ្នា និងអាចធ្វើការលើការស្រាវជ្រាវនេះ ដោយភាពងាយស្រួល និងជឿជាក់។

បង្កើតសកម្មភាពក្នុងការដោះស្រាយបញ្ហាដែលបានរកឃើញនិង ដំណោះស្រាយដែលលើកឡើងនៅក្នុងការស្រាវជ្រាវ។

# FPAR អាចគាំទ្រសហគមន៍ក្នុងការបង្កើតការចូលរួមជាយុទ្ធសាស្ត្រ តាមរយៈការស្រាវជ្រាវផ្អែកលើភស្តុតាង ដើម្បីលើកឡើងពីបញ្ហារបស់ពួកគាត់និងធ្វើអោយមានការផ្លាស់ប្តូរជាវិជ្ជមានលើបញ្ហាទាំងនោះ ដោយមានប្រសិទ្ធិភាព។



# ហេតុអ្វីត្រូវការ FPAR?
# តើវាមានសារៈសំខាន់យ៉ាង
# ណាក្នុងដំណើរឆ្ពោះទៅ
# កាន់សមភាពយេនឌ័រ?



# គោលការណ៍

# FPAR

*Feminist*
*Participatory*
*Action*
*Research*

១ គោលបំណងគឺចូលរួមចំណែកក្នុងការផ្លាស់ប្តូរជាវិជ្ជមាននូវរចនាសម្ព័ន្ធនិងទំនាក់ទំនងអំណាចតាមសង្កាត់

២ បន្លឺសំឡេងស្ត្រីនិងក្រុមងាយរងគ្រោះ

៣ សហគមន៍គឺជាម្ចាស់នៃការស្រាវជ្រាវFPAR

៤ ការប្រកាន់ខ្ជាប់នូវគោលការណ៍អន្តរប្រសព្វ

៥ ធ្វើការផ្លាស់ប្តូរទំនាក់ទំនងអំណាច តួយ៉ាង រវាងអ្នកស្រាវជ្រាវនិងអ្នកត្រូវបានស្រាវជ្រាវ

៦ បណ្តុះនិងកសាងសកម្មភាពរួមគ្នា

៧ កសាងសមត្ថភាពសហគមន៍

៨ ការយល់ព្រមចូលរួមដោយសេរីនិងទទួលបានព័ត៌មានគ្រប់ជ្រុងជ្រោយ

៩ សុវត្ថិភាព ការថែទាំ និងសាមគ្គីភាព

គោលបំណងគឺចូល
រួមចំណែកក្នុងការ
ផ្លាស់ប្ដូរជាវិជ្ជមាននូវ
រចនាសម្ព័ន្ធនិង
ទំនាក់ទំនងអំណាច
គាបសង្កត់



២ បន្លឺសំឡេងស្ត្រីនិង
ក្រុមងាយរងគ្រោះ

សហគមន៍ជា
ម្ចាស់នៃការ
ស្រាវជ្រាវFPAR

# ៤ ការប្រកាន់ខ្ជាប់នូវ
# គោលការណ៍
# អន្តរប្រសព្វ

ធ្វើការផ្លាស់ប្តូរទំនាក់ទំនង
អំណាចិ តុល្យ៉ាង រវាងអ្នក
ស្រាវជ្រាវនិងអ្នកត្រូវបាន
ស្រាវជ្រាវ

# ៥ បណ្ដុះនិងកសាង សកម្មភាពរួមគ្នា



# ៧ កសាងសមត្ថភាពសហគមន៍

# ៤ ការយល់ព្រមចូលរួមដោយ
# សេរីនិងទទួលបាន
# ព័ត៌មានគ្រប់ជ្រុងជ្រោយ



# សុវត្ថិភាព ការថែទាំ
# និងសាមគ្គីភាព

# “FPAR” Bingo



# សង្ខេបវិធីសាស្រ្ត ស្រាវជ្រាវ FPAR និងក្រុម សីលធម៌



# ជំហាននីមួយៗនៃអែហ្វផារ “FPAR”



## ជំហានទី១៖ ការបង្កើតប្រធានបទ

តើអ្នកចង់ស្វែងយល់ពីអ្វី?



## ជំហានទី២៖ ការរៀបចំនិងកំណត់ពេលវេលាស្រាវជ្រាវ

តើ ARs នឹងត្រូវការពេលវេលាប៉ុន្មាននៅក្នុងដំណើរការស្រាវជ្រាវ




## ជំហានទី៣៖ ការប្រកាសជ្រើសរើសអ្នកស្រាវជ្រាវ

វិធីសាស្ត្រមួយចំនួនដែលប្រើសម្រាប់ជ្រើសរើសអ្នកស្រាវជ្រាវ



## ជំហានទី៤៖ ការផ្តល់វគ្គបណ្តុះបណ្តាលស្តីពីFPAR & ហ្វេមីនីស្ត

មូលដ្ឋានគ្រឹះនិង បច្ចេកទេសនៃការស្រាវជ្រាវ



## ជំហានទី៥៖ ការបង្កើតឧបករណ៍ស្រាវជ្រាវ

បង្កើតកម្រងសំណួរស្ទាបស្ទង់មតិ និង/ឬ កម្រងសំណួរសម្ភាសន៍




## ជំហានទី៦៖ ការពិនិត្យ និងវិភាគឯកសារស្រាវជ្រាវ និងរបាយការណ៍មានស្រាប់

# ឧបករណ៍

- ការនិទានសាច់រឿង
- គំនូរ
- ការសម្តែង
- រូបថតសំឡេង
- ផែនទីខ្លួនប្រាណ
- ផែនទីសហគមន៍
- ផែនទីអំណាច
- តារាងពេលវេលា
- ការសម្តែង ល្ខោន ចំរៀង
- ការស្ទង់មតិ
- ការសម្ភាសន៍ និង KII
- ការពិភាក្សាក្រុម

# ជំហាននីមួយៗនៃអែហ្វផារ “FPAR”



## ជំហានទី៧៖ ការប្រមូលទិន្នន័យបឋមនៅសហគមន៍

ចាប់ផ្តើមបេសកម្ម និងធ្វើការស្រាវជ្រាវ!



## ជំហានទី៨៖ ប្រតិចារិក

ចាប់ផ្តើមកត់ត្រាប្រតិចារិកនៃបទសម្ភាសន៍



## ជំហានទី៩៖ ការបង្កើតកូដ និងវិភាគទិន្នន័យ

ការវិភាគទិន្នន័យ និងចុះកូដទិន្នន័យ



## ជំហានទី១០៖ ការបង្កើតសេចក្តីព្រាងរបាយការណ៍

បង្កើតចំណុចព្រាងនៃផ្នែកធំៗ និងផ្នែកផ្សេងៗគ្នា ដោយទទួលបានការយល់ស្រប ឬមតិកែលម្អពី ARs



## ជំហានទី១១៖ ការសរសេររបាយការណ៍ ការផ្ទៀងផ្ទាត់ និងកែសម្រួល



## ជំហានទី១២៖ ការផ្សព្វផ្សាយរបាយការណ៍តាមតម្រូវការ (សំណេរ ឬមិនមែនសំណេរ) និងតាក់តែងសកម្មភាពបន្ទាប់

ដូចជា វេទិការ គំនូរ ការសំដែងល្ខោន វីដេអូ ល។



# ក្រមសីលធម៌និងសុវត្ថិភាព នៅក្នុង FPAR

# សំណួរ៖

តើអ្វីជាគោលការណ៍ទី១ នៃការស្រាវជ្រាវប្រកបដោយក្រមសីលធម៌?

# គោលការណ៍មិនបង្ករគ្រោះថ្នាក់

# Do No Harm

**អ្នកស្រាវជ្រាវគួរតែ ប្រកាន់ខ្ជាប់នូវគោលការណ៍មិនបង្ករគ្រោះថ្នាក់៖**

- ការយល់ដឹងពីហានិភ័យនានាដែលអាចកើតមានដល់អ្នកចូលរួម (ការគំរាមកំហែង ហិង្សា សុវត្ថិភាព ភាពអាម៉ាស់ ល។)
- ការគោរពអ្នកចូលរួម
- ពួកយើងត្រូវតែធានាថា មិនមានការបង្ករគ្រោះថ្នាក់ចំពោះអ្នកចូលរួមរបស់ពួកយើង ជាលទ្ធផលនៃការចូលរួមរបស់ពួកគេ នៅក្នុងការស្រាវជ្រាវ។

ក្នុងនាមជាអ្នកស្រាវជ្រាវ ពួកយើងតែងតែធ្វើឱ្យមានតុល្យភាពគ្នា រវាងអត្ថប្រយោជន៍ និងហានិភ័យ។

# សំណួរ៖

តើមានហានិភ័យអ្វីខ្លះ ដែលអ្នកចូលរួមប្រឈម នៅក្នុងដំណើរការចូលរួម ការស្រាវជ្រាវ?

- បាត់បង់ឯកជនភាព និង ទំនុកចិត្ត
- ការធ្វើអោយទៅជាជនរង គ្រោះម្តងទៀត
- ហានិភ័យដែលអាចកើត មានដោយបង្កជាគ្រោះ ថ្នាក់ ឬក៏ផលវិបាកន្នានា ដែលមិនបានប្រសិនបើ បន្ទាប់ពីអត្តសញ្ញាណត្រូវ បានកំណត់

# ជំហានទាំង៤៖

# ក្រមសីលធម៌នៃការស្រាវជ្រាវ

## ជំហានទី ១

# ការទទួលបានការយល់ព្រមដោយជូនដំណឹងជាមុន

- ការស្ម័គ្រចិត្តដោយមិនមានការបង្ខិតបង្ខំរបស់អ្នកចូលរួមគឺជាការចាំបាច់។ គ្មានទម្រង់កិច្ចព្រមព្រៀង គ្មានការសម្ភាសន៍!
- យើងត្រូវតែធានាឱ្យបានថា យើងទទួលបានការព្រមព្រៀងពីអ្នកចូលរួមទាំងអស់ ដោយប្រើប្រាស់ទម្រង់កិច្ចព្រមព្រៀង។
- យើងត្រូវតែធានាផងដែរថា យើងបានផ្តល់ព័ត៌មានគ្រប់គ្រាន់ អំពីគម្រោងស្រាវជ្រាវ និងការប្រើប្រាស់ទិន្នន័យរបស់ពួកគេ ដើម្បីទទួលបានការយល់ព្រមពេញលេញ។ នេះអាចត្រូវបានធ្វើដោយ អានសេចក្តីថ្លែងការរបស់អ្នកចូលរួម។

## ជំហានទី ២

ធានាបាននូវលំហូរសុវត្ថិភាព ទាំងសម្រាប់អ្នកចូលរួម សម្ភាសន៍ និងអ្នកចុះទៅ សម្ភាសន៍

- ការយកចិត្តទុកដាក់គួរតែមាន ដើម្បីធានាថា បរិយាកាសមានផាសុកភាព មានឯកជនភាព និងរក្សាការសម្ងាត់របស់អ្នកចូលរួម។
    - អ្នកដទៃមិនពាក់ព័ន្ធមិនគួរស្តាប់លើកិច្ចសម្ភាសន៍
    - គួរតែមានទឹកសម្រាប់អ្នកចូលរួម។
    - ចូរចាំថា ការចុះទៅមើលទីតាំងជាមុន ដើម្បីឱ្យប្រាកដថាវាសមរម្យ។
    - ទីតាំងសមរម្យ អាចរួមបញ្ចូលទាំង ការិយាល័យអង្គការ ឬការិយាល័យនានា ប្រសិនបើពួកគេអាចផ្តល់ជូនបាន សម្រាប់ការសម្ភាសន៍ ដែលធានាបានឯកជនភាព។

# ជំហានទី ៣

# ការរក្សាបាននូវកន្លែងដែលគ្មានការវិនិច្ឆ័យ

- វាមិនមែនជាទំនួលខុសត្រូវរបស់អ្នកស្រាវជ្រាវទៅវិនិច្ឆ័យ ឬរើសអើងគ្នាទេ។ ជាពិសេស វាមានសារៈសំខាន់ក្នុងការធានាថា អ្នកមិននិយាយអំពីព័ត៌មានលម្អិតដែលអាចបកស្រាយថាជាការស្តីបន្ទោសចំពោះជនរងគ្រោះនៃអំពើហិង្សាលើយេនឌ័រ ណាមួយឡើយ។
- ប្រសិនបើអ្នកមិនយល់ស្រប ទៅហ្នឹងអ្វីដែលអ្នកអ្នកចូលរួមកំពុងនិយាយ កុំទៅឈ្លោះជាមួយពួកគាត់ អ្នកបានស្នើសុំពេលវេលា និងកត់ត្រានូវទស្សនៈរបស់ពួកគេ។ រក្សាភាពគួរសម ស្ងប់ស្ងាត់ មានសួរសំណួរបញ្ជាក់ដោយទន់ភ្លន់។
- បញ្ចប់កិច្ចសន្ទនា ដោយការកត់សម្គាល់ជាវិជ្ជមាន និងប្រាកដថាបាន និយាយអរគុណទៅកាន់អ្នកចូលរួមចំពោះពេលវេលារបស់ពួកគេ។

# ជំហានទី ៤

# ការរក្សាភាពអនាមិករបស់អ្នកចូលរួមក្រោយការសម្ភាសន៍

- គោលការណ៍ ក្រមសីលធម៌ស្រាវជ្រាវ មានន័យថា គោរពភាពឯកជនរបស់ជនរងគ្រោះ។ សូមចងចាំថា បន្ថែមពីកង្វល់ធម្មតាអំពីឯកជនភាព ការរក្សាការសម្ងាត់របស់អ្នកចូលរួមនៃការស្រាវជ្រាវអំពីអំពើហិង្សាក៏មានន័យថា ធានាសុវត្ថិភាពរបស់ពួកគេពីការសងសឹកផងដែរ។ វាសំខាន់ណាស់!
- អ្នកគួរប្រយ័ត្ន 'ការកំណត់អត្តសញ្ញាណ' នៅពេលដាក់ជាអនាមិកជន។ វាកើតឡើងនៅកន្លែងដែលអ្នកមើលភ្ជាប់ព័ត៌មានលម្អិត ដូចជាទីតាំង អាយុ សម្លៀកបំពាក់ ឬសមាជិកគ្រួសារ ទោះបីជាអ្នកមិនបញ្ចេញឈ្មោះជនរងគ្រោះ ឬមុខមាត់របស់ពួកគេ។

សូមចងចាំថា នៅតែបន្តការការពារឯកជនភាព និងការរក្សាការសម្ងាត់នៅក្នុងការសរសេររបាយការណ៍។មិនគួរប្រើប្រាស់ឈ្មោះពិតរបស់អ្នកចូលរួមនោះទេ ទោះបីជាពួកគាត់អនុញ្ញាតឱ្យធ្វើចឹងក៏ដោយ។

រក្សាទុកទិន្នន័យឱ្យមានសុវត្ថិភាព និងមិនគួរពិភាក្សា ឬចែករំលែកបទពិសោធន៍អំពើហិង្សាលើយេនឌ័រ ជាមួយសមាជិកសហគមន៍ដទៃទៀតទេ (រាប់តាំងពីអ្នកចូលរួមដទៃទៀត)

ធ្វើការស្នើសុំអ្នកចូលរួមដទៃទៀត នៅក្នុងកិច្ចពិភាក្សាជាក្រុម ដើម្បីរក្សាការសម្ងាត់នៃអ្នកចូលរួមដទៃទៀត។ នេះគួរតែជាផ្នែកនៃទម្រង់កិច្ចព្រមព្រៀងដែលពួកគេបានចុះហត្ថលេខាទាំងអស់គ្នា។




thank
you



# ករណីសិក្សា និងមេរៀន

https://wpmcambodia.org/project/voice-and-visibility-a-participatory-exploration-of-minority-womens-human-rights-in-cambodia/







ការស្រាវជ្រាវពី៖
«ស្ត្រីធ្វើការងារថែទាំមិនមានប្រាក់កម្រៃ និង
ថវិកាឆ្លើយតបតម្រូវការយេនឌ័រនៅថ្នាក់ឃុំ»

A research on
"Women Unpaid Cared Work and Gender
Responsive Budgeting at Commune Level"

GADC
Gender and Development for Cambodia

OXFAM


ទឹក និង ប្រេង ?
ការសិក្សាអំពីព្រះពុទ្ធសាសនា
និង លទ្ធិស្ត្រីនិយមនៅកម្ពុជា
ខែធ្នូ ឆ្នាំ២០២០
ក្លាហាន
klahaan


WATER & OIL?
A STUDY OF BUDDHISM &
FEMINISM IN CAMBODIA
DECEMBER 2020
ក្លាហាន
klahaan


ការងារផ្ទះ ៖
ជាការងាររបស់អ្នកណា?
ការសិក្សាស្រាវជ្រាវអំពីតួនាទីយេនឌ័រ ការងារថែទាំគ្មានប្រាក់កម្រៃ និងបន្ទុកផ្លូវចិត្តនៅកម្ពុជា។
កិច្ចការស្រាវជ្រាវបែបចូលរួម
ផ្អែកលើគោលការណ៍
klahaan
brave


Housework:
Whose work?
An exploration of gender roles, unpaid care work and the mental load in Cambodia.
A feminist
participatory action

# ផ្លូវបំបែក

ការសិក្សាអំពីផ្នត់គំនិតសង្គមលើការចែកផ្លូវគ្នា ការលែងលះ និងសិទ្ធិស្ត្រីនៅកម្ពុជា

ការស្រាវជ្រាវបែបចូលរួមផ្អែកលើគោលការណ៍លទ្ធិស្ត្រីនិយម

klahaan

# SEPARATE WAYS

A study of attitudes towards separation, divorce and women's rights in Cambodia.

A feminist participatory action research study

klahaan


វប្បធម៌
ព្រហ្មចារី
នៅកម្ពុជា
ការសិក្សាអំពីទស្សនៈសង្គម
២០
២១


VIRGINITY
CULTURE IN
CAMBODIA
20
21
A PERCEPTION STUDY



# បញ្ហាប្រឈម ឱកាស និង ជំហានបន្ទាប់


Q&A